# របៀបក្នុងការជ្រើសរើសជនពិការសម្រាប់កម្មវិធីទឹកស្អាតនិងលើកកម្ពស់ អនាម័យប្រកបដោយបរិយាបន្ន

មានជំហានជាច្រើនក្នុងការអនុវត្តដើម្បីជ្រើសរើសជនពិការឲ្យចូលរួមនៅក្នុងគម្រោងរបស់អង្គការ DDSP។

## ជំហានទី១៖ ការបង្ហាញព័ត៌មានពិការភាពនិងការណែនាំអំពីគម្រោង





ជាដំបូង អង្គការ DDSP បានរកឃើញព័ត៌មានដែលទាក់ទងនឹងជនពិការពីប្រភពទិន្នន័យដែលមានស្រាប់របស់ការិយាល័យផែនការស្រុក(DoP) និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាស្រុក(DoSVY)នៅក្នុងតំបន់គោលដៅដែលអង្គការ DDSPបានធ្វើការជាមួយ។

អង្គការ DDSP បានរៀបចំកិច្ចប្រជុំមួយជាមួយនឹងអាជ្ញាធរមូលដ្ឋានដើម្បីណែនាំគម្រោងថ្មីអំពីទឹកស្អាតនិងលើកកម្ពស់អនាម័យប្រកបដោយបរិយាបន្ន និងជូនដំណឹងដល់ក្រុមការងារអំពីការកំណត់ជនពិការដើម្បីចូលរួមក្នុងគម្រោង។



## ជំហានទី២៖ ការរៀបចំប្រជុំភូមិ



អង្គការ DDSP បានរៀបចំការប្រជុំផ្ទាល់ ជាមួយនឹងប្រធានភូមិនិងក្រុមប្រឹក្សាឃុំ ដើម្បីជូនដំណឹងពួកគេអំពីគោលបំណង នៃការសិក្សា ការជ្រើសរើសទីកន្លែងនិង ការកំណត់កាលបរិច្ឆេទសម្រាប់ការប្រជុំ ជាមួយនឹងអ្នកភូមិ។ អង្គការ DDSPចង់ ធានាឱ្យបានថាជនពិការនិងប្រជាជន ដែលក្រីក្រជាងគេត្រូវបានដាក់បញ្ចូល នៅក្នុងកិច្ចប្រជុំ។



ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរ មូលដ្ឋាន អង្គការDDSPបានរៀបចំកិច្ចប្រជុំ ជាមួយនឹងអ្នកភូមិដើម្បីផ្ដល់ព័ត៌មានទូទៅ អំពីគម្រោង និងបានរំលេចអំពីផល ប្រយោជន៍ក្នុងការចូលរួមនៅក្នុងគម្រោង ។

## ជំហានទី៣៖ការបង្កើតឧបករណ៍និងផ្ដល់វគ្គបណ្ដុះបណ្ដាលអំពីការប្រើប្រាស់ឧបករណ៍ដល់បុគ្គលិក



បញ្ជីសំនួរសម្រាប់ការសម្ភាសន៍(DDSP)

កាលបរិច្ឆេទនៃការសម្ភាសន៍៖ ________ ឈ្មោះអ្នកសម្ភាសន៍៖ ________

ទីកន្លែង៖ ឈ្មោះស្រុក________ ឈ្មោះឃុំ៖________ ឈ្មោះភូមិ៖________

១. ព័ត៌មានប្រជាសាស្ត្រ

| | | |
|---|---|---|
| ១.១ | ឈ្មោះរបស់ជនពិការ | |
| ១.២ | ភេទ | □ស្រី □ប្រុស |
| ១.៣ | អាយុ | |
| ១.៤ | តើអ្នកមានការពិបាកដែរឬទេ? | □ ការមើល បើទោះបីជាពាក់វ៉ែនតាក៏ដោយ?<br>□ ការស្តាប់ បើទោះបីជាពាក់ឧបករណ៍ជំនួយការស្តាប់ក៏ដោយ?<br>□ ការដើរ ឬឡើងជណ្តើរ?<br>□ ការចងចាំ ឬការផ្តង់អារម្មណ៍?<br>□ ជាមួយការថែទាំខ្លួនឯងដូចជាការងូតទឹក ឬការស្លៀកពាក់?<br>□ ការប្រើប្រាស់ភាសាធម្មតា ឬការទំនាក់ទំនង ឧទាហរណ៍ដូចជា យល់អ្នកដទៃ ឬឱ្យអ្នកដទៃយល់អ្នកជាដើម?<br>□ ផ្សេងៗ (សូមបញ្ជាក់ឲ្យបានជាក់លាក់)<br>.......................... |

ឧបករណ៍ប៉ាន់ប្រមាណគ្រួសារត្រូវបានបង្កើតឡើងដើម្បីប្រមូលព័ត៌មានអំពីពិការភាព ទឹកស្អាតនិងការលើកកម្ពស់អនាម័យ និងលទ្ធភាពទទួលបានសេវាផ្សេងៗ (សូមពិនិត្យមើលឧបសម្ព័ន្ធ៖ ឧបករណ៍ប៉ាន់ប្រមាណគ្រួសារ)។



វគ្គបណ្តុះបណ្តាលកន្លះថ្ងៃអំពីរបៀបក្នុងការប្រើប្រាស់ឧបករណ៍ ត្រូវបានរៀបចំឡើងសម្រាប់បុគ្គលិករបស់អង្គការDDSP។ ក្រោយពីបានសាកល្បងឧបករណ៍ជាមួយនឹងអ្នកភូមិនិងជនពិការ ឧបករណ៍ត្រូវបានកែសម្រួលឡើងវិញដោយមានការចូលរួមពីបុគ្គលិករបស់អង្គការDDSPដែលបានចូលរួមក្នុងការប្រមូលទិន្នន័យ។

## ជំហានទី៤៖ ការប្រមូលទិន្នន័យនៅកម្រិតភូមិ



ការសម្ភាសន៍ជាមួយគ្រួសារជាង ៥០០គ្រួសាររបស់ជនពិការនិងអ្នកភូមិដោយបុគ្គលិកអង្គការ DDSPនៅក្នុងស្រុកចំនួន៣ ឃុំចំនួន៨ និងភូមិចំនួន៥៩។

## ជំហានទី៥៖ ការជ្រើសរើសគ្រួសារ



ការជ្រើសរើសពាក់កណ្តាលគ្រួសារដោយអង្គការDDSPត្រូវបានផ្អែកលើលក្ខខណ្ឌ។ លក្ខខណ្ឌសម្រាប់ជ្រើសរើសពាក់កណ្តាលនៃគ្រួសារដែលបានជ្រើសរើសទាំងនោះមាន៖យ៉ាងហោចណាស់មានជនពិការត្រូវបានកំណត់ដោយមានប័ណ្ណគ្រួសារក្រីក្រ ខ្វះបង្គន់អនាម័យ មិនមានប្រភពទឹកនិងសមាជិកគ្រួសារដែលខ្វះការយល់ដឹងអំពីអនាម័យ។

ការជ្រើសរើសចុងក្រោយដោយមានការចូលរួមពីសហគមន៍និងកិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរមូលដ្ឋាន។
**សំគាល់៖** លក្ខខណ្ឌនៃការផ្តល់អណ្តូង បង្គន់ និងធុងចម្រោះមានលក្ខណៈខុសៗគ្នា។







**www.wateraid.org/cambodia**
S.I. Building 3rd Floor, #93, Preah Sihanouk Blvd,
Sangkat Chaktomuk, Phnom Penh, Cambodia
Tel: +855 17 935 083

WaterAid is a registered charity: Australia: ABN 99 700 687 141. Canada: 119288934 RR0001. India: U85100DL2010NPL200169. Sweden: Org.nr: 802426-1268, PG: 90 01 62-9, BG: 900-1629.
UK: 288701 (England and Wales) and SC039479 (Scotland). US: WaterAid America is a 501(c) (3) non-profit organization